**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

**លេខ** :.........០.១០/២០.........**ក.ប**/ស.ណ.ន.ខ.ល

# សេចក្តីណែនាំ

## ស្តីពី

## ការអនុវត្តការទូទាត់សងការឈប់សម្រាកពិសេស

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សូមជម្រាបជូនម្ចាស់ ឬនាយករោងចក្រ សហគ្រាស គ្រឹះស្ថាន សមាគមនិយោជក សហជីព និងកម្មករនិយោជិតទាំងអស់ឱ្យបានជ្រាបថា ដើម្បីឱ្យមានភាពច្បាស់លាស់ក្នុងការកំណត់អំពីរបៀបធ្វើការសង ក្នុងករណីឈប់សម្រាកពិសេស ដូចមានចែងក្នុងជំពូកទី៦ ផ្នែកទី៧ នៃច្បាប់ស្តីពីការងារ និងប្រកាសលេខ២៦៧ សកបយ ចុះថ្ងៃទី១១ ខែតុលា ឆ្នាំ២០០១ ស្តីពីការឈប់សម្រាកពិសេស ក្រសួងសូមធ្វើការណែនាំថា ការធ្វើការសងអាចអនុវត្តបានតែក្នុងរយៈពេល៩០ថ្ងៃក្រោយថ្ងៃឈប់សម្រាកពិសេស។ ការធ្វើការសងត្រូវអនុវត្តក្នុងថ្ងៃធ្វើការធម្មតា និងក្នុងលក្ខខណ្ឌដែលថិរវេលាធ្វើការសរុបមិនលើសពី ១០ម៉ោង ក្នុងមួយថ្ងៃ ឬលើសពី៥៤ម៉ោង ក្នុងមួយសប្តាហ៍។ មានន័យថា កម្មករនិយោជិតអាចធ្វើការសងបានតែ ៦ម៉ោង ក្នុងមួយសប្តាហ៍ប៉ុណ្ណោះនិងត្រូវទទួលបានប្រាក់ឈ្នួលក្នុងអត្រាប្រាក់ឈ្នួលម៉ោងការងារធម្មតា។ ប្រសិនបើកម្មករនិយោជិតធ្វើការលើសពី ៥៤ម៉ោង ក្នុងមួយសប្តាហ៍ ថិរវេលាដែលលើសនោះ និយោជកត្រូវផ្តល់ប្រាក់ឈ្នួលតាមអត្រាដំឡើង ដែលកំណត់ដោយច្បាប់ស្តីពីការងារ។

ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈមានក្តីសង្ឃឹមយ៉ាងមុតមាំថា ម្ចាស់ ឬនាយករោងចក្រ សហគ្រាស គ្រឹះស្ថាន សមាគមនិយោជក សហជីព និងកម្មករនិយោជិតទាំងអស់នឹងអនុវត្តតាមខ្លឹមសារសេចក្តីណែនាំនេះឱ្យបានត្រឹមត្រូវ និងមានប្រសិទ្ធភាព។

ថ្ងៃ សុក្រ ១៣រោច ខែ មាឃ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២១ ខែ កុម្ភៈ ឆ្នាំ២០២០

**រដ្ឋមន្ត្រី**

**អ៊ិត សំហេង**

**កន្លែងទទួល** :

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ក្រសួង ស្ថាប័នពាក់ព័ន្ធ

  "ដើម្បីជូនជ្រាប"
- មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈរាជធានី ខេត្ត
- សហជីព និងសមាគមនិយោជកគ្រប់លំដាប់ថ្នាក់

  "ដើម្បីអនុវត្ត"
- ឯកសារ កាលប្បវត្តិ

អាសយដ្ឋាន អគារលេខ៣ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក ទូរស័ព្ទ:(០២៣)៨៨ ៤៣ ៧៥ និងទូរសារ :(០២៣)៨៨ ២៧ ៦៩